ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ ១៧២ សស.រវណ-៩៨

# សេចក្តីបង្គាប់

## ស្តីពីការសុំកងកម្លាំងអាជ្ញាធរសាធារណៈចុះជួយអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

ខ្ញុំសូមជម្រាបមកអស់លោកប្រធានតុលាការ និងលោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត-ក្រុងថា តាមការសង្កេត និងតាមពាក្យបណ្តឹងតវ៉ាពីប្រជារាស្ត្រដែលឈ្នះក្តីតាមផ្លូវតុលាការរយៈកាលកន្លងមកនៅពេលអ្នកឈ្នះក្តីយកសាលក្រម ឬសាលដីកាស្ថាពរ ឬសេចក្តីសម្រេចផ្សេងៗរបស់តុលាការទៅសុំអោយតុលាការមូលដ្ឋានជួយអនុវត្តតាមសេចក្តីសម្រេចទាំងនោះ តុលាការត្រូវធ្វើលិខិតសុំគោលការណ៍យល់ព្រមជាមុនពីអាជ្ញាធរមូលដ្ឋានសិនទើបតុលាការអាចបំពេញបែបបទនៃនីតិវិធីចុះអនុវត្តជាក្រោយ ។ វិធានការណ៍នេះមិនស្របនឹងគោលការណ៍ និងច្បាប់ស្តីពីវិធីអនុវត្តសាលក្រមអនុម័តថ្ងៃទី០៦-០៤-៩២ ឡើយ ។

ក្រសួងយុត្តិធម៌សូមបញ្ជាក់ជូនលោកប្រធាន និងលោកព្រះរាជអាជ្ញាអមតុលាការថា ការអនុវត្តសាលក្រម ឬសាលដីកា ឬសេចក្តីសម្រេចផ្សេងៗរបស់តុលាការជាសិទ្ធិរបស់តុលាការ និងអយ្យការដែលច្បាប់បានប្រគល់ឱ្យ ។ ហេតុនេះអស់លោកត្រូវការតែកម្លាំងអនុវត្ត និងអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធីទេតែប៉ុណ្ណោះ ។

១-អំណើះតទៅ លោកប្រធាន ឬលោកព្រះរាជអាជ្ញាដែលជាអ្នកអនុវត្តសេចក្តីសម្រេចរបស់តុលាការក្រោយពីបានចាត់ការធ្វើសេចក្តីជូនដំណឹង និងបានធ្វើសេចក្តីបង្គាប់គ្រប់គ្រាន់សមស្របតាមច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរួចហើយ លោកគ្រាន់តែធ្វើលិខិតសុំកងកម្លាំងតាមចំនួនដែលត្រូវការពីអាជ្ញាធរមូលដ្ឋានឱ្យចូលរួមជួយតាមទីកន្លែង និងថ្ងៃខែឆ្នាំ ម៉ោងដែលបានកំណត់ (ឱ្យបានត្រឹមត្រូវតាមច្បាប់) តែប៉ុណ្ណោះបើអាជ្ញាធរមូលដ្ឋានណាពុំព្រមផ្តល់កម្លាំងឱ្យមកជួយតាមសំណូមពររបស់អ្នកអនុវត្តសាលក្រម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងធ្វើលិខិតជម្រាបទៅថ្នាក់លើ ដើម្បីឱ្យមានការគោរពច្បាប់ ។

២-រដ្ឋអំណាចមូលដ្ឋាន ដែលជាអង្គការនីតិប្រតិបត្តិ ពុំមានសិទ្ធិជ្រៀតជ្រែកក្នុងរឿងអនុវត្តការងាររបស់តុលាការ ឬរាំងដំណើរការរបស់តុលាការឡើយ ប៉ុន្តែសូមអស់លោកដោះស្រាយបញ្ហាជាមួយរដ្ឋអំណាចមូលដ្ឋានដោយរូបភាពទន់ភ្លន់ ដើម្បីរក្សាឱ្យបានដាច់ខាតនូវសាមគ្គីភាពផ្ទៃក្នុងជាមួយគ្នា ដោយឈរលើច្បាប់និងការយល់គ្នាទៅវិញទៅមក ។

ក្រសួងសង្ឃឹមថា អស់លោកនឹងអនុវត្តសេចក្តីបង្គាប់ការនេះឱ្យមានប្រសិទ្ធិភាពជាពុំខាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្នួន**

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អភិបាលខេត្ត.ក្រុង
-ដើម្បីជ្រាប និងជួយឧបត្ថម្ភ